Australian Government
Department of Education, Skills and Employment

Disability Standards for Education
2020 Review

# ការពិនិត្យឡើងវិញនៃស្តង់ដារមូលដ្ឋានពិការភាពក្នុងវិស័យអប់រំឆ្នាំ២០២០

## សេចក្តីផ្តើម

គោលបំណងនៃលិខិតពិភាក្សានេះត្រូវបានរៀបចំក្នុងគោលបំណងគាំទ្រនូវការពិគ្រោះយោបល់សម្រាប់ឆ្នាំ២០២០ (ហៅកាត់ការពិនិត្យឡើងវិញ) ដែលរៀបចំដោយរាជរដ្ឋាភិបាលរបស់ប្រទេសអូស្ត្រាលី នៃស្តង់ដារមូលដ្ឋានពិការភាពសម្រាប់ការអប់រំឆ្នាំ២០០៥ (ហៅកាត់ថា ស្តង់ដារមូលដ្ឋាន)។ នៅក្នុងលិខិតនេះ យើងនឹងពន្យល់ថាតើអ្វីទៅជាស្តង់ដារមូលដ្ឋាន និងតួនាទីរបស់ស្តង់ដារមូលដ្ឋានទាំងនោះ រួមទាំងគោលបំណង និងចំណុចដែលលោកអ្នកចូលរួមពីមុនបានប្រាប់ដល់ក្រុមការងារយើងខ្ញុំ និងអ្វីនាពេលអនាគតដែលលោកអ្នកអាចចូលរួមបាន។ លិខិតនេះក៏ផ្តល់ជូនជាមួយនឹងសំណួរខ្លះៗ ដើម្បីផ្តល់ជាមតិមកកាន់ក្រុមការងារយើងខ្ញុំផងដែរ។

**ការទទួលយក និងការចូលរួមក្នុងវិស័យអប់រំ ដើម្បីជួយបុគ្គលមានពិការភាពឱ្យមានសិទ្ធិពេញលេញក្នុងសង្គម** និងជម្រុញលើកទឹកចិត្តមិនថាស្ថានភាពណាក៏ដោយ។ **ផ្តល់ការសិក្សាស៊ីជម្រៅដែលឱ្យពួកគាត់ទទួលយកភាពជោគជ័យរបស់ពួកគាត់រៀងៗខ្លួននាពេលអនាគត** និងជម្រុញឱ្យពួកគាត់បន្តការសិក្សា ងាយស្រួលក្នុងការស្វែងរកការងារ និងលើកទឹកចិត្តខ្លួនឯង។

យោងតាមស្ថិតិឆ្នាំ២០១៨ របស់ Disability, Ageing and Carers (SDAC), ៤% នៃអាយុ ០ ដល់ ៤ ឆ្នាំ, ១០% នៃអាយុ ៥ ដល់ ១៩ ឆ្នាំ និង១៣% នៃអាយុ ១៥ ដល់ ៦៤ ឆ្នាំ ជាបុគ្គលដែលមានពិការភាព។ សរុបសេចក្តីមកក្នុងឆ្នាំ២០១៨, បុគ្គលដែលមានពិការភាពមាន១៧.៧% នៃចំនួនប្រជាជនអូស្ត្រាលីទាំងមូល ឬ ស្មើនឹងមនុស្សប្រមាណ៤.៣លាននាក់។

មិនត្រឹមតែប៉ុណ្ណោះ ក្នុងឆ្នាំ២០១៩ **ប្រហែលជាមួយក្នុងប្រាំ (១៩.៩%) នៃសិស្សសាលា**ទូទាំងផ្ទៃប្រទេសបានទទួលការសិក្សាដែលផ្តល់ជាពិសេសសម្រាប់ពួកគេ នេះដោយយោងទៅតាម Nationally Consistent Collection of Data ទៅលើ School Students with Disability (NCCD)។

## តួនាទីនៃស្តង់ដារមូលដ្ឋានក្នុងវិស័យអប់រំ

**ស្តង់ដារមូលដ្ឋានពិការភាពសម្រាប់ការអប់រំឆ្នាំ២០០៥** (ហៅកាត់ថា ស្តង់ដារមូលដ្ឋាន) បានចូលជាធរមាននៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥។ ស្តង់ដារនេះមានតួនាទីធានាឱ្យបុគ្គលមានពិការភាពអាច**ទទួលយក និងចូលរួមក្នុងវិស័យអប់រំដូចទៅនឹងបុគ្គលដែលគ្មានពិការភាពដែរ**។

ស្តង់ដារមូលដ្ឋាននេះស្ថិតនៅក្រោមបង្គាប់នៃច្បាប់ ការពារ និងលុបបំបាត់ការរើសអើងជនពិការ ឆ្នាំ១៩៩២ (Disability Discrimation Act 1992) ដែលហៅកាត់ថា DDA; ហេតុដូច្នោះហើយស្តង់ដារមូលដ្ឋាននេះគឺស្ថិតនៅក្រោមច្បាប់ដែលបានចែង។ យោងទៅតាម DDA **វាជារឿងខុសច្បាប់ប្រសិនបើមនុស្សម្នាក់បានរើសអើងជនមានពិការភាព**។ DDAនឹងជួយការពារបុគ្គលទាំងឡាយណាដែលមានពិការភាពគ្រប់សកម្មភាព រួមទាំងការចូលរួម។

យោងទៅតាម ផ្នែក២ ជំពូក២ នៃ DDA **អគ្គព្រះរាជអាជ្ញាមានសិទ្ធិបន្ថែមស្តង់ដារមូលដ្ឋានពិការភាព** ទៅលើសិទ្ធិ និងមុខងារដែលទាក់ទងទៅនឹងភាពទទួលបានស្មើគ្នារបស់បុគ្គលដែលមានពិការភាព**ពីលើស្តង់ដារមូលដ្ឋានពិការភាពបន្ថែមទៀត**។

នេះគឺជាស្តង់ដារមូលដ្ឋានពិការភាពដែលបានចែងក្រោម DDA:

- ស្តង់ដារមូលដ្ឋានពិការភាព ក្នុងវិស័យដឹកជញ្ជូនសាធារណ:ឆ្នាំ២០០២
- ស្តង់ដារមូលដ្ឋានពិការភាព ក្នុងវិស័យអប់រំឆ្នាំ២០០៥
- ស្តង់ដារមូលដ្ឋានពិការភាព ទៅលើការប្រើប្រាស់អគារ និងទីកន្លែងផ្សេងៗឆ្នាំ២០១០

ប្រសិនជាបុគ្គលណាមួយគោរពទៅតាមការណែនាំរបស់ស្តង់ដារមូលដ្ឋានពិការភាព បុគ្គលរូបនោះគឺត្រូវតែគោរពទៅតាមDDAផងដែរ។ **គ្រឹះស្ថានអប់រំត្រូវតែគោរពទៅតាមស្តង់ដារមូលដ្ឋាន** បើពុំដូច្នោះទេគឺត្រូវចាត់ទុកជាមោឃៈ។

# គោលបំណងនៃស្តង់ដារមូលដ្ឋានពិការភាព ក្នុងវិស័យអប់រំ

គោលបំណងនៃស្តង់ដារមូលដ្ឋានគឺដើម្បីសម្តែងឱ្យច្បាស់ពីទំនាក់ទំនងរវាងវិស័យអប់រំ និងDDA។ សំខាន់បំផុតទៅទៀតនោះ ស្តង់ដារមូលដ្ឋាននឹង**ឱ្យយើងយល់ច្បាស់ពីសិទ្ធិ និងតួនាទី**ដោយយោងទៅតាមDDA។

ស្តង់ដារមូលដ្ឋានមានចែងទាក់ទងទៅនឹង៖

- **ការចុះឈ្មោះចូលរៀន**
- **ការចូលរួម**
- **ការអភិវឌ្ឍន៍កម្មវិធីសិក្សា**
- **ការទទួលស្គាល់ជាផ្លូវការ និងការបង្រៀន**
- **ការគាំទ្រ និងជំនួយដល់សិស្សានុសិស្ស**
- **ការលុបបំបាត់ចោលការធ្វើបាបយាយី និងការរងគ្រោះ**

គ្រប់ផ្នែកនៃស្តង់ដារមូលដ្ឋានចែងថា៖

- **សិទ្ធិរបស់សិស្សានុសិស្សដែលមានពិការភាព** (នេះបូកបញ្ចូលសិស្សានុសិស្សដែលមិនបានចុះឈ្មោះ) ដែលទាក់ទងទៅនឹងការអប់រំ និងការបង្រៀនដែលអនុញ្ញាតឱ្យលោកអ្នកស្គាល់ និងយល់អំពីស្តង់ដារមូលដ្ឋានថាតើអ្វីទៅជាសិទ្ធិស្មើគ្នា និងសមហេតុផល
- **កាតព្វកិច្ចច្បាប់ ឬ តួនាទីរបស់គ្រឹះស្ថានអប់រំ**
- **វិធានការ និងគោលដៅ**ដែលផ្តល់ជាឧទាហរណ៍ថាតើអ្វីដែលគួរសម្រេចដើម្បីឈានដល់គោលដៅនៃស្តង់ដារមូលដ្ឋាននីមួយៗ។

គ្រឹះស្ថានអប់រំដែលស្ថិតនៅក្រោមស្តង់ដារមូលដ្ឋាននេះមានដូចជាសាលាមត្តេយ្យ បឋមសិក្សារដ្ឋ និងឯកជន, វិទ្យាស្ថានអប់រំបច្ចេកទេស និងបន្ថែមវិជ្ជា (Techinical and Further Education: TAFE)នានា សាលាបន្ថែមចំណេះ(Vocational Education and Training: VET), សាលាមនុស្សពេញវ័យ និងគ្រឹះស្ថានអប់រំជាន់ខ្ពស់ដទៃៗទៀត។

## កាតព្វកិច្ចសម្រាប់ការកែតម្រូវតាមការគួរ

ស្តង់ដារមូលដ្ឋានបានផ្តល់សិទ្ធិឱ្យគ្រឹះស្ថានអប់រំ**សម្រាប់កែតម្រូវដ៏សមហេតុផលតាមការគួរតាមគ្រឹះស្ថាននីមួយៗ** ដើម្បីរៀបចំឱ្យសិស្សានុសិស្សដែលមានពិការភាពអាចទទួលបានការអប់រំដូចនឹងសិស្សានុសិស្សដទៃៗទៀត។

គ្រឹះស្ថានអប់រំត្រូវតែ**ពិភាក្សាជាមួយសិស្ស ឪពុកម្តាយ និងអាណាព្យាបាលអំពីការកែតម្រូវនេះ**។ គ្រឹះស្ថានទាំងនោះក៏ត្រូវតែគិតពិចារណាប្រសិនជាការកែតម្រូវនោះប៉ះពាល់ដល់បុគ្គលិក សិស្សានុសិស្សដទៃទៀត និងត្រូវតែរក្សាតម្លៃនៃកម្មវិធីសិក្សា និងកិច្ចការប្រឡងនានា។

ស្តង់ដារមូលដ្ឋានក៏បានចែងអំពីលក្ខខណ្ឌផ្សេងៗដែលគ្រឹះស្ថានអប់រំមិនត្រូវបានអនុញ្ញាតឱ្យមានការកែតម្រូវ ប្រសិនបើការតម្រូវនោះនឹងធ្វើឱ្យមាន**ភាពលំបាកដល់គ្រឹះស្ថានក្នុងស្ថានការណាមួយ**។ ការលើកលែងនេះមិនត្រូវបានលើកលែងទៅលើការធ្វើបាបយាយី និងការរងគ្រោះនានា។

## ការដាក់ពាក្យបណ្តឹងតវ៉ា

ប្រសិនជាបុគ្គលណាមួយគិតថាគ្រឹះស្ថានអប់រំមិនបានធ្វើតាមស្តង់ដារមូលដ្ឋាន លោកអ្នក**មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ទៅកាន់គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្សអូស្ត្រាលី** (Australian Human Rights Commission: AHRC) អំពីការរើសអើងនេះ។ AHRC នឹងព្យាយាមឱ្យអស់ពីសមត្ថភាពក្នុងការដោះស្រាយនូវបណ្តឹងតវ៉ាទាំងនោះ។

ប្រសិនជា AHRC មិនបានសម្រេចសេចក្តីដ៏សមស្របណាមួយ **លោកអ្នកអ្នកដាក់ពាក្យបណ្តឹងតវ៉ាជាផ្លូវច្បាប់** ទៅតាមតុលាការឧទ្ធរណ៍ (Federal Courst of Australia) ឬ តុលាការសៀគ្វី (Federal Circuit Court)។

# ការពិនិត្យឡើងវិញឆ្នាំ២០១០ និងឆ្នាំ២០១៥

ការពិនិត្យឡើងវិញឆ្នាំ២០១០ នៃស្តង់ដារមូលដ្ឋានបានក្លាយជាក្របខណ្ឌ ដើម្បីផ្សព្វផ្សាយអំពីការទទួលបាន និងការចូលរួមនៅក្នុងប្រព័ន្ធអប់រំ ប៉ុន្តែនៅមានចំណុចខ្លះៗដែលនៅតែមិនទាន់បានទទួលបានលទ្ធផលល្អប្រសើរ។ ការពិនិត្យឡើងវិញឆ្នាំ២០១៥ បានរកឃើញថា ខណៈពេលដែលមានការកែសម្រួលការពិនិត្យឡើងវិញឆ្នាំ២០១០ ក៏នៅតែមានកន្លែងខ្លះដែលត្រូវការ ការត្រួតពិនិត្យ និងកែសម្រួល។

ចំណុចទូទៅដែលបានផ្តោតសំខាន់នៅក្នុងស្តង់ដារមូលដ្ឋានឆ្នាំ២០១០ និង២០១៥មានដូចជា៖

- **ការលើកកម្ពស់ការយល់ដឹង** - អាចត្រូវបានធ្វើឡើងបន្ថែមទៀតដើម្បីធានាថាស្តង់ដារមូលដ្ឋានមានការផ្តោតសំខាន់ទៅលើអ្នកប្រើប្រាស់ ហើយត្រូវបានលើកកម្ពស់យ៉ាងទូលំទូលាយ និងងាយយល់។
- **ការច្បាស់លាស់ ការយល់ដឹង និងសមត្ថភាព** - ការពន្យល់បកស្រាយ និងការប្រើពាក្យដូចជា “ការកែសម្រួលសមហេតុផល” និង “ការលំបាកដែលមិនសមហេតុផល” នឹងត្រូវការឯកសារយោងបន្ថែមទៀត ថាតើយើងគួរតែឱ្យអត្ថន័យនៃពាក្យទាំងនោះដោយផ្អែកទៅលើអ្វី។
- **បណ្តឹងតវ៉ា** - ការដាក់ពាក្យតវ៉ាសម្រាប់ស្តង់ដារមូលដ្ឋានអាចនឹងត្រូវចំណាញពេលវេលាច្រើន ដែលនាំជាផលលំបាកសម្រាប់អ្នកដាក់ពាក្យបណ្តឹងដូចជាសិស្សានុសិស្ស សមាជិកគ្រួសាររបស់ពួកគេ និងអាណាព្យាបាល។
- **ការទទួលខុសត្រូវ និងការអនុលោមភាព** - ការពឹងផ្អែកលើយន្តការបណ្តឹងតវ៉ាដើម្បីជម្រុញឱ្យមានការអនុលោមតាមស្តង់ដារមូលដ្ឋានមិនមានប្រសិទ្ធភាព និងអាចត្រូវបានបន្ថែមជាមួយនឹងយន្តការដទៃៗបន្ថែមទៀត។

នៅពេលដែលមានប្រធានបទស្រដៀងគ្នាដែលបានចែងនៅក្នុងការពិនិត្យឡើងវិញឆ្នាំ២០២០ ក្រុមការងារយើងនឹងពិនិត្យមើលវិសាលភាពនៃការរីកចម្រើនទាំងនោះដើម្បីដោះស្រាយគិតតាំងពីឆ្នាំ២០១៥ រួមទាំងកំណែទម្រង់ថ្នាក់ជាតិ និងរដ្ឋសំខាន់ៗដើម្បីគាំទ្រដល់សិស្ស និងជនមានពិការភាព។

ក្រុមការងារយើងទទួលស្គាល់នូវអនុសាសន៍មួយចំនួនពីការពិនិត្យឡើងវិញឆ្នាំ២០១៥ ប៉ុន្តែក្រុមការងារយើងខ្ញុំមិនមានការរីកចម្រើនក្នុងការដោះស្រាយបញ្ហាទាំងនោះនៅឡើយទេ។ យើងនឹងពិចារណាលើអ្វីដែលជាផ្នែកមួយនៃការត្រួតពិនិត្យទាំងនោះ និងព្យាយាមដោះស្រាយនូវបញ្ហាទាំងនោះ។

# ការត្រួតពិនិត្យស្តង់ដារមូលដ្ឋាន ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំតម្រូវឱ្យមានការពិនិត្យឡើងវិញនូវស្តង់ដារមូលដ្ឋានរៀងរាល់៥ឆ្នាំម្តង** ដោយមានការពិគ្រោះពិភាក្សាជាមួយនឹងព្រះរាជអាជ្ញា។

ការពិនិត្យឡើងវិញអាចធ្វើបាន ប្រសិនជាស្តង់ដារមូលដ្ឋានអាចឈានទៅរកគោលបំណងមានដូចជា៖

*(ក)ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងជនពិការ នៅតាមមូលដ្ឋានរបស់គ្រឹះស្ថានអប់រំ*

*និងការបណ្តុះបណ្តាលនានាឱ្យបានតាមដែលអាចធ្វើទៅបាន និង*

*(ខ)ដើម្បីធានាថាជនពិការមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់នៅក្នុងវិស័យអប់រំ*

*និងវគ្គបណ្តុះបណ្តាលនានាដូចជាបុគ្គលទូទៅនៅក្នុងសហគមន៍ដទៃទៀតផងដែរ និង*

*(គ)ដើម្បីលើកកម្ពស់ការទទួលស្គាល់  និងការទទួលយកនៅក្នុងសហគមន៍នៃគោលការណ៍របស់ជនពិការដែលមាន*

*សិទ្ធិជាមូលដ្ឋានដូចគ្នាទៅនឹងសហគមន៍ដទៃៗទៀត។*

**អ្វីដែលសំខាន់គឺការត្រួតពិនិត្យឡើងវិញសួរថាតើស្តង់ដារមូលដ្ឋានទាំងនោះកំពុងដើរតួយ៉ាងសំខាន់ក្នុងសង្គមដែរ ឬ ទេ? ប្រសិនជាអត់តើយើងគួរតែកែលម្អយ៉ាងដូចម្តេច?**

# វិសាលភាព និងការផ្តោតសំខាន់នៃការត្រួតពិនិត្យឆ្នាំ២០២០

ដើម្បីឱ្យដឹងថាស្តង់ដារមូលដ្ឋានកំពុងធ្វើការតាមអ្វីដែលបានចែង
ក្រុមការងារយើងនឹងត្រូវទទួលយកយោបល់អំពីសកម្មភាពរាល់ថ្ងៃពីសិស្សានុសិស្ស គ្រួសាររបស់ពួកគេ និងអាណាព្យាបាល,
គ្រឹះស្ថានអប់រំរបស់ពួកគេ, គ្រូរបស់ពួកគេ និងអ្នកតំណាងរបស់ពួកគេ។

ក្រុមការងាររបស់យើងក៏ត្រូវនិយាយជាមួយនឹងរាជរដ្ឋាភិបាលនៃរដ្ឋនីមួយៗ អាជ្ញាធរអប់រំ ទីភ្នាក់ងារជាតិ និយតករ
និងអ្នកតំណាងនៃវិស័យនានាដែលមិនមែនជារាជរដ្ឋាភិបាល។

ការប្រើប្រាស់ចំណេះដឹង និងការយល់ដឹងដែលក្រុមការងារយើងទទួលបានមក
អាចកំណត់បានថាតើស្តង់ដារមូលដ្ឋានដំណើរការល្អប៉ុណ្ណាដែលជាយន្តការសម្រាប់បកស្រាយ DDA ទាក់ទងទៅនឹងការអប់រំ
និងការបណ្តុះបណ្តាល។

## លក្ខខណ្ឌសម្រាប់ការត្រួតពិនិត្យឆ្នាំ២០២០

ក្នុងការពិចារណាពីប្រសិទ្ធភាពនៃស្តង់ដារមូលដ្ឋានការពិនិត្យឡើងវិញនឹងពិចារណាដូចខាងក្រោមៈ

1. តើ**សិទ្ធិ កាតព្វកិច្ច និងវិធានការនៃការអនុលោមតាមច្បាប់**បានកំណត់នៅក្នុងស្តង់ដារមូលដ្ឋាន (និងគោលការណ៍ណែនាំរបស់វា) **មានភាពច្បាស់លាស់ និងសមស្របដែរ ឬ ទេ**?
2. តើសិស្សានុសិស្ស សមាជិកក្រុមគ្រួសារ និងអាណាព្យាបាល អ្នកអប់រំ គ្រឹះស្ថានអប់រំ និងអ្នកបង្កើតគោលនយោបាយ**ដឹងអំពី ស្វែងយល់អំពី អនុវត្ត និងគោរពតាម**សិទ្ធិកាតព្វកិច្ច និងវិធាននៃការអនុលោមតាមមូលដ្ឋានដែរ ឬ ទេ?
3. ក្នុងរយៈពេល១៥ ឆ្នាំចាប់តាំងពីស្តង់ដារមូលដ្ឋានត្រូវបានបង្កើតឡើង **តើមូលដ្ឋានបានចូលរួមចំណែកដល់សិស្សដែលមានពិការភាពឱ្យមានលទ្ធភាពទទួលបានឱកាសសិក្សា និងបណ្តុះបណ្តាល**នៅលើមូលដ្ឋានដូចគ្នានឹងសិស្សដែលគ្មានពិការភាពដែរ ឬ ទេ?

ការពិគ្រោះយោបល់សម្រាប់ការពិនិត្យឡើងវិញនឹងរួមបញ្ចូល**ការផ្តោតទៅលើ**ផលប៉ះពាល់នៃស្តង់ដារមូលដ្ឋានស្តីពីមូល**ពិសោធន៍របស់សិស្សានុសិស្សដែលមានពិការភាពមកពី ជនជាតិAboriginal  និងជនជាតិ Torrens Strait Islander ដែរ ឬ ទេ**

ក្នុងការបង្កើតអនុសាសន៍ស្តីពី**ការពិនិត្យឡើងវិញនឹងផ្តោតសំខាន់ទៅលើឱកាសសម្រាប់សកម្មភាពសហប្រតិបត្តិការថ្នាក់ជាតិរវាងយុត្តាធិការ និងទីភ្នាក់ងារ** រួមទាំងសកម្មភាពពង្រឹងចំណេះដឹង និងសមត្ថភាពរបស់គ្រូ និងអ្នកអប់រំ
**តើការធ្វើវិសោធនកម្មស្តង់ដារមូលដ្ឋានណាមួយ**គួរតែត្រូវផ្លាស់ប្តូរ?

## វិសាលភាពនៃការត្រួតពិនិត្យឡើងវិញ

ក្រុមការងារយើងទទួលស្គាល់ថា
មានការពិភាក្សាកាន់តែទូលំទូលាយអំពីវិធីសាស្ត្រល្អៗនានាក្នុងការផ្តល់ការអប់រំដល់សិស្សដែលមានពិការភាពដែលត្រូវបានផ្សាយចេញនៅក្នុងការពិនិត្យ និងការសាកសួរជាច្រើនទៀតព្រមទាំងបន្តការពិគ្រោះតាមរយៈគណៈកម្មការទទួលបន្ទុកអំពើហឹង្សា ការរំលោភបំពាន ការធ្វេសប្រហែស និងការកេងប្រវ័ញ្ចប្រជាពលរដ្ឋ និងជនពិការ (ហៅកាត់ថាគណៈកម្មការជនពិការ)។
ក្រុមការងារយើងទទួលស្គាល់ថាមានទស្សនៈរឹងមាំអំពីបញ្ហានានាដូចជាការអប់រំបញ្ចូលគ្នា និងអត្ថិភាពនៃសាលាពិសេស ឬ កន្លែងសិក្សាដាច់ដោយឡែកក៏ដូចជាឱកាសសម្រាប់សិស្សដែលមានពិការភាព។
វាជាការសំខាន់ក្នុងការកត់សម្គាល់ថាបញ្ហាមួយចំនួនស្ថិតនៅខាងក្រៅវិសាលភាពនៃការត្រួតពិនិត្យឡើងវិញនេះ។

**សំណួរសំខាន់សម្រាប់ការត្រួតពិនិត្យឡើងវិញនេះ**
**តើកម្រិតស្តង់ដារមូលដ្ឋានកំពុងធ្វើឱ្យមានការផ្លាស់ប្តូរវិជ្ជមាន**ចំពោះសិស្សដែលមានពិការភាព
ឱ្យមានលទ្ធភាពទទួលបានឱកាសការអប់រំ និងការបណ្តុះបណ្តាលនៅលើមូលដ្ឋានដូចគ្នានឹងសិស្សដែលគ្មានពិការភាពដែរ ឬ ទេ?
ដើម្បីឆ្លើយសំណួរនេះយើងត្រូវការជំនួយរបស់លោកអ្នក។

# តើធ្វើដូចម្តេចដើម្បីចូលរួមចំណែកនៃការត្រួតពិនិត្យនេះ

យើង**ស្វាគមន៍ចំពោះមតិយោបល់លើផ្នែកណាមួយនៃស្តង់ដារមូលដ្ឋាននេះពីប្រជាពលរដ្ឋទាំងឡាយណា**ដែលចង់ចូលរួមក្នុងការបញ្ចេញមតិ។ នេះរួមបញ្ចូលទាំងមនុស្សវ័យក្មេងដែលនៅតែមាននៅក្នុងប្រព័ន្ធអប់រំ រហូតដល់អ្នកតំណាងនានា
**ក្រុមការងារយើងខ្ញុំចង់ដឹងពីមតិពីមនុស្សកាន់តែច្រើនកាន់តែល្អ**។

ការចូលរួមចំណែកទាំងអស់នឹងជួយបង្កើនការយល់ដឹងរបស់យើងអំពីមូលពិសោធន៍របស់លោកអ្នក
និង**ជួយយើងឱ្យសម្រេចគោលដៅនៃស្តង់ដារមូលដ្ឋាននេះ**។

ក្រុមការងារយើងខ្ញុំសូមលើកកម្ពស់ការបញ្ចេញមតិពីយុវជន យុវនារី និងចង់ដឹងអំពីមូលពិសោធន៍ពីជនជាតិAboriginal
និងជនជាតិ Torrens Strait Islander ដែលមានពិការភាព ព្រមទាំងសមាជិកក្រុមគ្រួសារ និងអាណាព្យាបាលរបស់ពួកគេ។

ការពិគ្រោះយោបល់ជាសាធារណៈរបស់យើងនឹងដំណើរការជិតបីខែចាប់ពីខែកក្កដា ឆ្នាំ២០២០។
យើងនឹងផ្តល់ជូនលោកអ្នកនូវវិធីជាច្រើនដើម្បីចូលរួម និងអាចបញ្ចេញមតិបាន។
នៅពេលកាលបរិច្ឆេទសម្រាប់ការពិគ្រោះយោបល់ត្រូវបានបញ្ជាក់ច្បាស់ លោកអ្នកអាចចូលទៅកាន់គេហទំព័រ Review website។

នៅលើគេហទំព័រ លោកអ្នកអាចសរសេរ ថតជាវីដេអូ និងសម្លេងផ្ទាល់របស់លោកអ្នក ឬ បំពេញកម្រងសំណួរ។
យើងខ្ញុំក៏នឹងមានឱកាសពិគ្រោះយោបល់តាមប្រព័ន្ធអ៊ីនធឺណែតជាច្រើនផងដែរ
ដែលលោកអ្នកអាចបង្ហាញចំណាប់អារម្មណ៍របស់លោកអ្នកឱ្យបាន។

ដោយសារជំងឺរាតត្បាតកូវីដ-១៩
ការពិគ្រោះយោបល់ភាគច្រើននឹងធ្វើតាមប្រព័ន្ធអ៊ីនធឺណែតទោះយ៉ាងណាយើងនឹងធ្វើការពិគ្រោះយោបល់ដោយជួបគ្នាផ្ទាល់ជាមួយលោកអ្នកនៅពេលដែលអាចធ្វើបាន។

សម្រាប់ព័ត៌មានបន្ថែម លោកអ្នកអាចចូលទៅកាន់ Review website ឬ ចុះឈ្មោះ sign up ដើម្បីបានព័ត៌មានបន្ថែមទាក់ទងនឹងការពិគ្រោះយោបល់នេះ។

# ការបញ្ចេញមតិ

ក្រុមការងារយើង**ចង់ស្តាប់នូវទស្សនៈ និងយោបល់របស់លោកអ្នក**។
សំណួរខាងក្រោមនេះអនុញ្ញាតឱ្យលោកអ្នកគិតទុកជាមុនថា**តើលោកអ្នកគួរតែផ្តល់ជាយោបល់ដូចម្តេចទៅក្នុងការត្រួតពិនិត្យឡើងវិញ**។

លោកអ្នកអាចឆ្លើយសំណួរខាងក្រោម ឬ ផ្តល់ជាយោបល់តាមមធ្យោបាយផ្សេងៗទៀតដូចបានរៀបរាប់ដូចខាងលើ។
សំណួរខាងក្រោមគ្រាន់តែជាការណែនាំដើម្បីជួយឱ្យយើងយល់ពីទស្សនៈ
និងមូលពិសោធន៍របស់លោកអ្នកតែប៉ុណ្ណោះទាក់ទងទៅនឹងស្តង់ដារមូលដ្ឋាន។

នៅពេលផ្តល់ចម្លើយមកដល់ក្រុមការងារយើងខ្ញុំ សូមលោកអ្នកប្រាប់យើងខ្ញុំថាតើលោកអ្នកជាសិស្ស ឪពុកម្តាយ / អាណាព្យាបាល ឬ អ្នកអប់រំ (នេះរួមបញ្ចូលទាំងគ្រូបណ្តុះបណ្តាល និងអ្នកវាយតម្លៃនានា) អ្នកតំណាងមតិ អ្នកផ្តល់ការអប់រំ ឬ មានតួនាទីផ្សេងៗទៀត។
នៅពេលដែលសមរម្យសូមលោកអ្នកប្រាប់យើងផងដែរថាតើយោបល់ទាំងនោះទាក់ទងទៅនឹងវិស័យអ្វី? ឧទាហរណ៍ សាលាមត្តេយ្យ សាលារៀនចំណេះដឹងទូទៅ វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ សាកលវិទ្យាល័យ។

## សំណួរសម្រាប់សិស្សានុសិស្ស និងមាតាបិតា ឬ អាណាព្យាបាល

**សូមប្រាប់ពួកយើងអំពីមូលហេតុ បទពិសោធន៍ដែលលោកអ្នកទទួលយកបាន នៅពេលចូលរួមក្នុងវិស័យអប់រំ៖**

- ការចុះឈ្មោះចូលរៀន និងការចូលរៀន៖ តើលោកអ្នកមានមូលពិសោធន៍ដូចម្តេចខ្លះក្នុងការទទួលយកការអប់រំ? តើលោកអ្នកបានឆ្លងកាត់ការចុះឈ្មោះចូលរៀនដោយមានមូលពិសោធន៍ដូចម្តេចខ្លះ?
- ការចូលរួមចំណែក៖ តើគ្រឹះស្ថានអប់រំបានសម្របខ្លួនដើម្បីលោកអ្នក ឬ កូនរបស់លោកអ្នកក្នុងការចូលរួមសកម្មភាពសិក្សា? សកម្មភាពសិក្សាមានដូចជា មុខវិជ្ជាបង្រៀន កម្មវិធីសិក្សា និងការប្រើប្រាស់អគារសិក្សានានា។ តើគ្រឹះស្ថានអប់រំបានពិគ្រោះជាមួយលោកអ្នកដូចម្តេចខ្លះ? តើលោកអ្នកពេញចិត្តនឹងលទ្ធផលនៃការសម្រេចចិត្តទាំងនោះដែរ ឬ ទេ?
- ជួយសិស្សានុសិស្ស៖ តើលោកអ្នក ឬ កូនរបស់លោកអ្នកបានទទួលជំនួយពីគ្រឹះស្ថានអប់រំដែរ ឬ ទេ? ការទទួលជំនួយនេះមានដូចជា ការគាំទ្រ និងការពារការស្វែងរកជំនួញនានា ដូចជាសម្ភារៈផ្សេងៗ។
- ការយាយី និងការរងទទួលរងគ្រោះនានា៖ តើលោកអ្នក ឬ កូនរបស់លោកអ្នកបានទទួលការយាយី ឬ ជាជនរងគ្រោះនៅក្នុងគ្រឹះស្ថានអប់រំដែរ ឬ ទេ? ប្រសិនជាដែរ តើមានរឿងអ្វីកើតឡើង? តើលោកអ្នក ឬ គ្រឹះស្ថានអប់រំបានធ្វើដូចម្តេចខ្លះក្នុងបញ្ហានេះ?
- បណ្តឹងតវ៉ា៖ ប្រសិនជាលោកអ្នកគិតថាគ្រឹះស្ថានអប់រំណាមួយមិនបានប្រព្រឹត្ត ឬ គោរពទៅតាមតួនាទីរបស់គ្រឹះស្ថានអប់រំនោះ តើលោកអ្នកត្រូវធ្វើដូចម្តេច? តើលោកអ្នកដឹងអំពីពិធីដាក់ពាក្យបណ្តឹងតវ៉ាដែរ ឬ ទេ? តើមានរឿងអ្វីកើតឡើង?
- ការផ្លាស់ប្តូរសាលា៖ តើលោកអ្នកបានប្រាប់យើងខ្ញុំបានទេចំពោះមូលពិសោធន៍ទទួលយកការអប់រំ និងការគាំទ្រពីគ្រឹះស្ថានអប់រំខណៈពេលដែលផ្លាស់ប្តូរពីសាលាមួយ ទៅសាលាមួយទៀត ឧទាហរណ៍ ការផ្លាស់ប្តូរសាលាចាស់ទៅកាន់ឧត្តមសិក្សា។
- សិស្សានុសិស្សជនជាតិAboriginal  និងជនជាតិ Torrens Strait Islanderដែលមានពិការភាព៖ តើលោកអ្នកអាចប្រាប់ពីមូលពិសោធន៍របស់លោកអ្នក ឬ កូនរបស់លោកអ្នកក្នុងការទទួលយកការអប់រំបានដែរ ឬ ទេ?
- មូលពិសោធន៍ដទៃៗទៀត៖ ការទទួលបាន និងចូលរួមក្នុងវិស័យអប់រំសម្រាប់សិស្សានុសិស្សដែលមានពិការភាព ពេលខ្លះមានផលវិបាកដូចជា អាយុ ភេទ យេនឌ័រ កំណត់សម្គាល់យេនឌ័រ ប្រភេទនៃភេទ ស្ថានភាពភេទប្រសព្វគ្នា ទីកន្លែងកំណើត ជនជាតិ វប្បធម៌ ប្រពៃណី និងភាសា។ តើលោកអ្នកអាចប្រាប់ពីមូលពិសោធន៍របស់លោកអ្នក ឬ កូនរបស់លោកអ្នកក្នុងការទទួលយកការអប់រំបានដែរ ឬ ទេ?
- កូវីដ១៩៖ ខណៈពេលជំងឺកូវីដ១៩ តើលោកអ្នក ឬ កូនរបស់លោកអ្នកបានរងផលប៉ះពាល់ដល់ការសិក្សាអប់រំដែរ ឬ ទេ? តើលោកអ្នកធ្លាប់ជួបប្រទះបញ្ហាធំៗនានាដូចជាគ្រោះធម្មជាតិដែរ ឬ ទេ? តើវាមានធ្វើឱ្យលោកអ្នក ឬ កូនរបស់លោកអ្នកបានរងផលប៉ះពាល់ដល់ការសិក្សាអប់រំដែរ ឬ ទេ?

**ក្រុមការងារយើងចង់ដឹងអំពីយោបល់លោកអ្នកបន្ថែមទៀតទៅលើស្តង់ដារមូលដ្ឋាន**

- តើលោកអ្នកស្គាល់ និងដឹងពីមូលហេតុនៃការបង្កើតស្តង់ដារមូលដ្ឋាននេះដែរ ឬ ទេ? ប្រសិនជាស្គាល់ តើលោកអ្នកបានស្គាល់ពីស្តង់ដារមូលដ្ឋាននេះតាមវិធីណា?
- តើលោកអ្នក និងកូនរបស់លោកអ្នកបានយល់ និងស្គាល់ពីសិទ្ធិរបស់លោកអ្នកក្នុងដើម្បីចូលរួមក្នុងវិស័យអប់រំដែរ ឬ ទេ?
- តើលោកអ្នកអាចប្រាប់យើងបានដែរ ឬ ទេ តើស្តង់ដារមូលដ្ឋាននេះបានជួយលោកអ្នក និងកូនរបស់លោកអ្នកឱ្យស្គាល់ពីសិទ្ធិរបស់លោកអ្នក និងកូនរបស់លោកអ្នកយ៉ាងណាខ្លះ?

- តើលោកអ្នកគិតថាស្តង់ដារមូលដ្ឋាននេះជួយសិស្សានុសិស្សដែលមានពិការភាព ឱ្យមានភាពស្មើគ្នាក្នុងការចូលរួម និងទទួលយកការអប់រំដូចនឹងសិស្សដទៃដែរ ឬ ទេ? ហេតុអ្វី?
- តើលោកអ្នកគិតថាស្តង់ដារមូលដ្ឋាននេះជួយសិស្សានុសិស្សជនជាតិAboriginal និងជនជាតិ Torrens Strait Islanderដែលមានពិការភាពឱ្យមានភាពស្មើគ្នាក្នុងការចូលរួម និងទទួលយកការអប់រំដូចនឹងសិស្សដទៃដែរ ឬ ទេ? ហេតុអ្វី?

ការពិនិត្យឡើងវិញនេះនឹងជួយឱ្យក្រុមការងារយើងដឹងថាតើចំណុចណាក្នុងស្តង់ដារមូលដ្ឋានដែលនឹងត្រូវកែសម្រួល និងអំពីការអនុវត្តន៍ស្តង់ដារមូលដ្ឋាននោះទៅក្នុងសង្គម។ **ក្រុមការងារយើងចង់ដឹងអំពីមតិយោបល់របស់អស់លោកអ្នក។**

- តើនៅមានការរារាំងដែលបង្កជាផលវិបាកក្នុងការទទួលយកការអប់រំដោយសិស្សានុសិស្សដែលមានពិការភាពដែរ ឬ ទេ? ប្រសិនជាមាន តើលោកអ្នកគិតថាយ៉ាងដូចម្តេចដែលស្តង់ដារមូលដ្ឋានគួរតែធ្វើដូចម្តេច?
- តើស្តង់ដារមូលដ្ឋានគួរតែផ្លាស់ប្តូរដែរ ឬ ទេ? ហេតុអ្វី?
- តើត្រូវធ្វើដូចម្តេចដើម្បីឱ្យស្តង់ដារមូលដ្ឋានមានការរីកចម្រើន?
- តើត្រូវមានសម្ភារៈ ឬ ឯកសារណាខ្លះដើម្បីជួយឱ្យលោកអ្នកយល់អំពីស្តង់ដារមូលដ្ឋាននេះ?
- តើលោកអ្នកស្គាល់ គោលការណ៍ណែនាំ (Guidance Notes) នៃស្តង់ដារមូលដ្ឋានដែរ ឬ ទេ ហើយលោកអ្នកគិតថាវាមានប្រយោជន៍ដែរ ឬ ទេ? ហេតុអ្វី?

តើស្តង់ដារមូលដ្ឋាននេះត្រូវធ្វើដូចម្តេចដើម្បីជួយសិស្សានុសិស្សជនជាតិAboriginal និងជនជាតិ Torrens Strait Islanderដែលមានពិការភាព?

## សំណួរសម្រាប់អ្នកផ្តល់ចំណេះវិជ្ជា វិទ្យាស្ថាន និងគ្រឹះស្ថានអប់រំនានា

**សូមប្រាប់ពួកយើងអំពីពិសោធន៍**ដែលលោកអ្នកមានជាមួយសិស្សានុសិស្សដែលមានពិការភាព។

- ការចុះឈ្មោះចូលរៀន និងការចូលរៀន៖
  តើលោកអ្នកមានបទពិសោធន៍ដូចម្តេចខ្លះជាមួយសិស្សានុសិស្សដែលមានពិការភាពក្នុងការទទួលយកការអប់រំ?
- ការចូលរួមចំណែក៖
  តើលោកអ្នកយល់អំពីភារកិច្ចរបស់លោកអ្នកក្នុងការសម្របសម្រួលសេចក្តីត្រូវការជាមួយសិស្សានុសិស្សដែលមានពិការភាពឱ្យមានលទ្ធភាពចូលរួមនៅក្នុងវិស័យអប់រំដែរ ឬ ទេ? នេះបូកបញ្ចូលទាំងសកម្មភាពសិក្សាមានដូចជា មុខវិជ្ជាបង្រៀន កម្មវិធីសិក្សា និងការប្រើប្រាស់អគារសិក្សានានា។
  តើលោកអ្នកដឹងអំពីទាក់ទងជាមួយនឹងសិស្សានុសិស្ស ឪពុកម្តាយ ឬ អាណាព្យាបាលដែរ ឬ ទេ?
  ប្រសិនជាលោកអ្នកធ្លាប់មានបទពិសោធន៍ក្នុងការសម្របសម្រួល
  សូមលោកអ្នកចែករំលែងបទពិសោធន៍នោះជាមួយក្រុមការងារយើងខ្ញុំ។
- ជួយសិស្សានុសិស្ស៖ តើគ្រឹះស្ថានអប់រំបានផ្តល់ជាជំនួយគ្រប់គ្រាន់ដែរ ឬ ទេទៅលើសិស្សានុសិស្សដែលមានពិការភាពក្នុងការទទួលយកការអប់រំ? ការទទួលជំនួយនេះមានដូចជា ការគាំទ្រ និងការពារការស្វែងរកជំនួញនានា ដូចជាសម្ភារៈផ្សេងៗ។
- ការយីយា និងការរងទទួលរងគ្រោះនានា៖ តើលោកអ្នកធ្លាប់ប្រទះឃើញសិស្សានុសិស្សដែលមានពិការភាពទទួលការយីយា ឬ ជាជនរងគ្រោះនៅក្នុងគ្រឹះស្ថានអប់រំដែរ ឬ ទេ? តើគ្រឹះស្ថានអប់រំបានធ្វើដូចម្តេចខ្លះក្នុងបញ្ហានេះ?
- បណ្តឹងតវ៉ា៖ តើលោកអ្នកធ្លាប់ត្រូវបានសិស្សានុសិស្សដែលមានពិការភាព ឪពុកម្តាយ ឬ អាណាព្យាបាលបានប្រាប់លោកអ្នកថា លោកអ្នកមិនបានប្រព្រឹត្ត ឬ គោរពទៅតាមតួនាទីរបស់គ្រឹះស្ថានអប់រំដែរ ឬ ទេ? តើលោកអ្នកបានឆ្លើយតបដូចម្តេចខ្លះ?
- ការផ្លាស់ប្តូរសាលា៖
  តើលោកអ្នកបានប្រាប់យើងខ្ញុំបានទេចំពោះពិសោធន៍ជួយសិស្សានុសិស្សដែលមានពិការភាពទទួលយកការអប់រំ និងការគាំទ្រពីគ្រឹះស្ថានអប់រំខណៈពេលដែលផ្លាស់ប្តូរពីសាលាមួយ ទៅសាលាមួយទៀត ឧទាហរហ៍ ការផ្លាស់ប្តូរសាលាចាស់ទៅកាន់ឧត្តមសិក្សា។
- សិស្សានុសិស្សជនជាតិAboriginal  និងជនជាតិ Torrens Strait Islanderដែលមានពិការភាព៖
  តើលោកអ្នកអាចប្រាប់ពីពិសោធន៍របស់លោកអ្នកក្នុងការគាំទ្រ និងផ្តល់ជាជំនួយដល់សិស្សានុសិស្សជនជាតិAboriginal និងជនជាតិ Torrens Strait Islanderដែលមានពិការភាព។ តើលោកអ្នកបានជួយពួកគាត់ដូចម្តេចខ្លះ?
  តើលោកអ្នកបានពិគ្រោះជាមួយពួកគាត់ និងគ្រួសារ ឬ អាណាព្យាបាលរបស់ពួកគាត់ដែរ ឬ ទេ?
- មូលពិសោធន៍ដទៃៗទៀត៖ ការទទួលបាន និងចូលរួមក្នុងវិស័យអប់រំសម្រាប់សិស្សានុសិស្សដែលមានពិការភាពពេលខ្លះមានផលវិបាកដូចជា អាយុ ភេទ យេនឌ័រ កំណត់សម្គាល់យេនឌ័រ ប្រភេទនៃភេទ ស្ថានភាពភេទប្រសព្វគ្នា ទីកន្លែងកំណើត ជនជាតិ វប្បធម៌ ប្រពៃណី និងភាសា។ តើលោកអ្នកអាចប្រាប់ពីមូលពិសោធន៍របស់លោកអ្នក ឬ កូនរបស់លោកអ្នកក្នុងការទទួលយកការអប់រំបានដែរ ឬ ទេ?
- កូវីដ១៩៖ ខណៈពេលជំងឺកូវីដ១៩ តើលោកអ្នក ឬ សិស្សានុសិស្សរបស់លោកអ្នកបានរងផលប៉ះពាល់ដល់ការសិក្សាអប់រំដែរ ឬ ទេ?
  តើលោកអ្នកធ្លាប់ជួបប្រទះបញ្ហាធំៗនានាដូចជាគ្រោះធម្មជាតិដែរ ឬ ទេ? តើវាមានធ្វើឱ្យលោកអ្នក ឬ សិស្សានុសិស្សរបស់លោកអ្នកបានរងផលប៉ះពាល់ដល់ការសិក្សាអប់រំដែរ ឬ ទេ?

**ក្រុមការងារយើងចង់ដឹងអំពីយោបល់លោកអ្នកបន្ថែមទៀតទៅលើស្តង់ដារមូលដ្ឋាន**

- តើលោកអ្នកស្គាល់ និងដឹងពីមូលហេតុនៃការបង្កើតស្តង់ដារមូលដ្ឋាននេះដែរ ឬ ទេ? ប្រសិនជាស្គាល់ តើលោកអ្នកបានស្គាល់ពីស្តង់ដារមូលដ្ឋាននេះតាមវិធីណា?
- តើលោកអ្នកធ្លាប់បានទទួលការបង្រៀនអំពីស្តង់ដារមូលដ្ឋាន ឬ ផ្នែកណាមួយនៃស្តង់ដារមូលដ្ឋានដែរ ឬ ទេ? ផ្នែកទាំងអស់បានបង្រៀនលោកអ្នកអំពីអ្វីខ្លះ?
- តើលោកអ្នកយល់ពីកាតព្វកិច្ចរបស់លោកអ្នកដែរ ឬ ទេនៅពេលនិយាយដល់សិស្សានុសិស្សដែលមានពិការភាពដែលអាចទទួលបាន និងចូលរួមចំណែកក្នុវិស័យអប់រំ? តើស្តង់ដារមូលដ្ឋាននេះបានជួយលោកអ្នកឱ្យយល់ពីកាតព្វកិច្ចរបស់អ្នកយ៉ាងដូចម្តេច?
- តើលោកអ្នកមានអារម្មណ៍ថាមានទំនុកចិត្តក្នុងការចរចា និងអនុវត្តតាមការកែតម្រូវដែរ ឬ ទេ? តើលោកអ្នកត្រូវធ្វើដូចម្តេចប្រសិនជាជួបបញ្ហាដែលនាំឱ្យមានផលលំបាក?
- តើលោកអ្នកគិតថាស្តង់ដារមូលដ្ឋាននេះជួយសិស្សានុសិស្សដែលមានពិការភាព ឱ្យមានភាពស្មើគ្នាក្នុងការចូលរួម និងទទួលយកការអប់រំដូចនឹងសិស្សដទៃដែរ ឬ ទេ? ហេតុអ្វី?
- តើលោកអ្នកគិតថាស្តង់ដារមូលដ្ឋាននេះជួយសិស្សានុសិស្សជនជាតិAboriginal  និងជនជាតិ Torrens Strait Islanderដែលមានពិការភាពឱ្យមានភាពស្មើគ្នាក្នុងការចូលរួម និងទទួលយកការអប់រំដូចនឹងសិស្សដទៃដែរ ឬ ទេ? ហេតុអ្វី?

ការពិនិត្យឡើងវិញនេះនឹងជួយក្រុមការងារយើងខ្ញុំក្នុងការស្វែងរកចំណុចខ្វះខាត និងពិធីសាស្រ្តក្នុងការដោះស្រាយ។
**ក្រុមការងារយើងចង់ស្តាប់អំពីរបស់អស់លោកអ្នកក្នុងការអភិវឌ្ឍន៍ស្តង់ដារមូលដ្ឋាននេះ។**

- តើលោកអ្នកគិតថានៅមានការរារាំងដែលបង្កជាផលវិបាកក្នុងការទទួលយកការអប់រំដោយសិស្សានុសិស្សដែលមានពិការភាពដែរ ឬ ទេ?
- តើស្តង់ដារមូលដ្ឋានគួរតែផ្លាស់ប្តូរដែរ ឬ ទេ? ហេតុអ្វី?
- តើត្រូវធ្វើដូចម្តេចដើម្បីឱ្យស្តង់ដារមូលដ្ឋានមានការរីកចម្រើន?
- តើត្រូវមានសម្ភារៈ ឬ ឯកសារណាខ្លះដើម្បីជួយឱ្យលោកអ្នកយល់អំពីស្តង់ដារមូលដ្ឋាននេះ?
- តើលោកគិតថា គោលការណ៍ណែនាំ (Guidance Notes) នៃស្តង់ដារមូលដ្ឋានមានប្រយោជន៍ដែរ ឬ ទេ? មូលហេតុអ្វី?
- តើស្តង់ដារមូលដ្ឋាននេះត្រូវធ្វើដូចម្តេចដើម្បីជួយសិស្សានុសិស្សជនជាតិAboriginal  និងជនជាតិ Torrens Strait Islanderដែលមានពិការភាព?

## ការអប់រំ និងការថែទាំកុមារតូចៗ និងស្តង់ដារមូលដ្ឋាន

នៅក្នុងបរិបទនៃការអប់រំ និងការថែរក្សាកុមារតូចៗ ស្តង់ដារមូលដ្ឋានបច្ចុប្បន្នត្រូវបានអនុវត្តចំពោះសាលាមត្តេយ្យ និងបឋមសិក្សា ប៉ុន្តែមិនទាន់បានរាប់បញ្ចូលគ្រឹះស្ថានថែទាំកុមារនោះទេ។

ការពិនិត្យឡើងវិញទាំងឆ្នាំ២០១០ និងឆ្នាំ២០១៥ បានរកឃើញថាមានការភាន់ច្រលំខ្លះៗនៅក្នុងវិស័យអប់រំ និងការថែទាំកុមារតូចៗអំពីការរំពឹងទុក និងទំនួលខុសត្រូវ ម៉្យាងទៀតអ្នកផ្តល់សេវាថែទាំកុមារ និងវិស័យថែទាំកុមារដំបូងៗ ត្រូវបានស្ថិតនៅក្រោមស្តង់ដារមូលដ្ឋាន។
ការពិនិត្យឡើងវិញបានផ្តល់ការពិចារណាលើការពង្រីកការអនុវត្តស្តង់ដារមូលដ្ឋានទាំងនោះដល់អ្នកផ្តល់សេវាថែទាំកុមារតូចៗ។

មន្ត្រីមកពីរាជរដ្ឋាភិបាលអូស្ត្រាលីថ្នាក់ជាតិ និងរាជរដ្ឋាភិបាលថ្នាក់មូលដ្ឋានបានអនុវត្តការងាររួមដើម្បីពិចារណាពីផលប៉ះពាល់ និងផលប៉ះពាល់នៃការផ្លាស់ប្តូរស្តង់ដារមូលដ្ឋានដើម្បីពង្រីក និងពង្រឹងទៅក្នុងវិស័យថែទាំកុមារ។
ទាំងអស់នេះរួមបញ្ចូលទាំងវិសាលភាពដែលស្តង់ដារមូលដ្ឋាននឹងគាំទ្រយ៉ាងច្បាស់លាស់ និងការយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចក្រោម DDA ដែលទាក់ទងនឹងការអប់រំ និងការថែរក្សាកុមារតូចៗ។

ការពិចារណាទៅលើការពង្រីកសក្តានុពលនៃស្តង់ដារមូលដ្ឋានទៅនឹងការរៀបចំ និងការថែទាំកុមារតូចៗផ្សេងៗទៀតដែលនឹងត្រូវបានសាកល្បងតាមរយៈការពិនិត្យឡើងវិញ និងការពិគ្រោះយោបល់ទាក់ទងទៅនឹងស្តង់ដារមូលដ្ឋាន។
**ក្រដាសពិភាក្សាដាច់ដោយឡែកមួយ**នឹងត្រូវបានបោះពុម្ពផ្សាយនៅក្នុងខែសីហា ដើម្បីស្វែងរកបទពិសោធន៍របស់លោកអ្នកទាក់ទងនឹងស្តង់សារបទដ្ឋាន និងDDAក្នុងវិស័យអប់រំ និងការថែទាំកុមារតូចៗរួមទាំងទស្សនៈរបស់អ្នកទៅថ្ងៃអនាគត។

## ភាពងាយស្រួល

ដើម្បីជួយធានាថាបុគ្គលដែលមានពិការភាពអាចចូលរួមជាមួយនឹងការពិនិត្យឡើងវិញនេះ និងចែករំលែកការយល់ដឹង និងបទពិសោធន៍របស់ពួកគេ ការពិគ្រោះយោបល់នឹងមានឯកសារងាយស្រួលអាន អ្នកបកប្រែភាសាគរ និងមានចំណងជើង។ ឯកសារងាយស្រួលអាន
និងសម្ភារៈផ្សេងៗទៀតនឹងត្រូវបានផ្តល់ជូនជាមុនដើម្បីជួយឱ្យពួកគាត់មានព័ត៌មានដែលពួកគាត់ត្រូវការ។
ការពិនិត្យឡើងវិញនេះនឹងផ្តោតពិចារណាទៅលើចំណូលចិត្តរបស់អ្នកចូលរួមកម្មវិធី ទៅតាមអ្វីដែលពួកគេចង់ចែករំលែកទៅតាមបទពិសោធន៍របស់ពួកគេ។ ពួកគាត់អាចជ្រើសរើសវិធីដែលពួកគេចង់ចូលរួម រួមមានការឆ្លើយសំណួរតាមពេលវេលាផ្ទាល់ខ្លួនតាមប្រព័ន្ធអ៊ីនធឺណែត ឬ ចូលរួមការពិភាក្សាផ្តល់។
ក្រុមការងារយើងនឹងខិតខំឱ្យអស់ពីសមត្ថភាពដើម្បីធានាបាននូវឱកាសរួមទាំងរយៈពេល និងការពិគ្រោះយោបល់ដែលសមស្របនឹងតម្រូវការ រួមទាំងសំណូមពររបស់ប្រជាពលរដ្ឋ។

## ការពិគ្រោះយោបល់ជាសាធារណៈនេះនឹងផ្តល់ជាដំបូន្មានឱ្យយើងដល់រដ្ឋាភិបាល

ការចូលរួមរបស់លោកអ្នកក្នុងការពិនិត្យឡើងវិញនេះនឹងផ្តល់នូវការយល់ដឹងដល់ក្រុមការងារយើងថា តើស្តង់ដារមូលដ្ឋាននេះត្រូវបានបំពេញតាមគោលបំណងដែលបានរៀបរាប់ និងរបៀបដែលស្តង់ដារមូលដ្ឋាននេះកំពុងដំណើរការសម្រាប់សិស្សានុសិស្ស។

ប្រសិនបើយើងឃើញថាស្តង់ដារមូលដ្ឋាននេះនាពេលបច្ចុប្បន្នមិនដំណើរការល្អ ឬ មានកន្លែងដែលអាចកែលម្អណាមួយ ក្រុមការងារយើងនឹងឱ្យយោបល់ទៅលើអ្វីដែលត្រូវមានការផ្លាស់ប្តូរ និងអំពីរបៀបផ្លាស់ប្តូរ រួមជាមួយនឹងពេលដែលមានការផ្លាស់ប្តូរក្របខណ្ឌដែលត្រូវបានអនុវត្ត។

ក្រុមការងារយើងនឹងធ្វើកិច្ចការនេះក្នុងភាពជាដៃគូជាមួយនឹងរាជរដ្ឋាភិបាលមូលដ្ឋានដែលយើងនឹងធ្វើការយ៉ាងជិតស្និទ្ធ និងសហការគ្នាដើម្បីបង្កើតរបាយការណ៍ចុងក្រោយនិងអនុសាសន៍ទាក់ទងនឹងរបាយការណ៍ទាំងនោះ។
គោលបំណងរបស់យើងគឺផ្តោតសំខាន់ទៅលើឱកាសសម្រាប់សកម្មភាពសហប្រតិបត្តិការថ្នាក់ជាតិរវាងរាជរដ្ឋាភិបាលអូស្ត្រាលីមូលដ្ឋាន និងរដ្ឋាភិបាលថ្នាក់ជាតិ និងអ្នកផ្តល់ការអប់រំដែលមិនមែនជារាជរដ្ឋាភិបាល។

របាយការណ៍ព្រាងពិនិត្យទាំងអស់នឹងត្រូវផ្តល់ជូនរដ្ឋមន្ត្រីក្រសួងអប់រំថ្នាក់ជាតិនៅខែធ្នូ ឆ្នាំ២០២០។ របាយការណ៍ចុងក្រោយ នឹងត្រូវប្រគល់ជូនគណៈរាជរដ្ឋាភិបាលទាំងអស់ធ្វើការពិចារណានៅដើមឆ្នាំ២០២១ ។

## ការដាក់សំណុំរឿង

ប្រជាពលរដ្ឋ និងអង្គភាពទាំងអស់អាចដាក់សំណុំរឿងមកកាន់គេហទំព័រ [link].

យើងអាចទទួលយកការដាក់សំណុំរឿងទាំងអស់នោះជាការសរសេរ វីដេអូ និងសម្លេង។
ការសរសេរត្រូវបានកំណត់ត្រឹមតែ៣០០០ពាក្យតែប៉ុណ្ណោះ។

ប្រសិនជាការដាក់សំណុំរឿងទាំងអស់មិនអាចដាក់ក្នុងគេហទំព័រមាន លោកអ្នកអាចផ្ញើមកកាន់អាសយដ្ឋានៈ

Disability Standards for Education Review Team
Disability Strategy Taskforce
GPO Box 9880
Canberra City ACT 2601

## ទំនាក់ទំនង

សម្រាប់ការពិនិត្យឡើងវិញ ដូចជាលិខិតស្នាមនានា សូមលោកអ្នកទាក់ទងមកកាន់ ក្រសួងអប់រំ ជំនាញ និងការងារ (Department of Education, Skills and Employment) តាមរយៈអ៊ីម៉ែល DisabilityStrategy@dese.gov.au.

សម្រាប់របៀប និងដើម្បីចូលរួមការប្រជុំ ដូចជាការចុះឈ្មោះ និងរបៀបចូលរួមកិច្ចពិភាក្សា ឬ ជំនួយក្នុងការបំពេញសំណួរនានា សូមលោកអ្នកទាក់ទងមកកាន់ ការិយាល័យគុមុខ (The Social Deck) តាមរយៈអ៊ីម៉ែល engage@thesocialdeck.com.